ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាខាសមាគមមិត្តបុគ្គលិកកសិកម្មកម្ពុជា**
**អគ្គនាយកដ្ឋានកសិកម្ម**

ថ្ងៃ ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

លេខ.............អនក/សបក រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ២០១៨

**សូមគោរពជូន**

**ឯកឧត្តមប្រធានគណៈកម្មាធិការសមាគមមិត្តបុគ្គលិកកសិកម្មកម្ពុជា**

**កម្មវត្ថុ៖** របាយការណ៍ ស្តីពីការយកថវិកាសមាគម ទៅប្រគល់ជូនគ្រួសារសពលោកស្រី ប៊ីប ម៉ាវ៉ាន់ ដែលបានទទួលមរណភាពកាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៧ នៅសង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

**សូមជូនភ្ជាប់៖**លិខិតថ្លែងអំណរគុណរបស់ក្រុមគ្រួសារនៃសពចំនួន៖..........................................០១ច្បាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូនឯកឧត្តមប្រធានគណៈកម្មាធិការសមាគមមិត្តបុគ្គលិកកសិកម្មកម្ពុជាមេត្តាជ្រាបថា កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ វេលាម៉ោង១៤,០០ នាទីរសៀល ថ្នាក់ដឹកនាំនាយកដ្ឋានវិស្វកម្មកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្មនិងមន្ត្រីអមដំណើររួមមាន៖

លោក ញ៉ែម សុខា អនុប្រធាននាយកដ្ឋានវិស្វកម្មកសិកម្ម

លោកស្រី វ៉ុត សុជាតិ អនុប្រធានការិយាល័យ រ.ជ.គ.ស នៃនាយកដ្ឋានវិស្វកម្មកសិកម្ម

លោក តាន់ មហោណារ៉ូ មន្ត្រីនាយកដ្ឋានវិស្វកម្មកសិកម្ម

លោក កុយ ផល មន្ត្រីជាប់កិច្ចសន្យាបំរើការងារនៅនាយកដ្ឋានវិស្វកម្មកសិកម្មទទួលបន្ទុក ស.ប.ក

លោក ហ៊ឹម ឈៀង មន្ត្រីជាប់កិច្ចសន្យាបំរើការងារនៅនាយកដ្ឋានវិស្វកម្មកសិកម្ម

បានយកថវិការបស់សមាគមមិត្តបុគ្គលិកកសិកម្មកម្ពុជាទៅប្រគល់ជូនលោក ស៊ូ សំណាង ត្រូវជាគ្រួសារនៃសព នៅសង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ក្នុងពិធីនោះ លោកប្រធានគណៈប្រតិភូបានសំណេះសំណាលសួរសុខ ទុក្ខ ចំពោះគ្រួសារសព និងប្រគល់ជូនលោក ស៊ូ សំណាង ត្រូវជាប្តីនៃសពនូវ៖

- ថវិកាចំនួន ៣.០០០ ០០០រ (បីលានរៀលគត់) និងឯកសារពាក់ព័ន្ធ

នៅទីបញ្ចប់ក្រុមគ្រួសារនៃសព លោកប្រធានភូមិ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តមរដ្ឋមន្ត្រី ដែលតែងតែយកចិត្តទុកដាក់ដល់ជីវភាពរស់នៅរបស់មន្ត្រីរាជការ និងសូមគោរពជូនពរឯកឧត្តមរដ្ឋមន្ត្រី ឯកឧត្តមរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការនិងថ្នាក់ដឹកនាំមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមបានទទួលនូវពុទ្ធពរទាំងឡាយ៤ប្រការគឺ អាយុៈ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រធានគណៈកម្មាធិការសមាគមមិត្តបុគ្គលិកកសិកម្មកម្ពុជា មេត្តាជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ។

សូមឯកឧត្តមប្រធាន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ៕

**ប្រធានគណៈកម្មាធិការសាខាស.ប.ក**
**នៃអគ្គនាយកដ្ឋានកសិកម្ម**

-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតថ្លែងអំណរគុណ
## ជូនឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

យើងខ្ញុំទាំងអស់គ្នា ជាក្រុមគ្រួសារនៃសពលោកស្រី ប៉ឹប ម៉ាក់ន់ ដែលបានទទួលមរណភាពកាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៧ នៅសង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ត្រូវជាប្រពន្ធលោកស៊ូ សំណាង មន្ត្រីចូលនិវត្តនាយកដ្ឋានវិស្វកម្មកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម និងជាសមាជិកសមាគមមិត្តបុគ្គលិកកសិកម្មកម្ពុជា ។

យើងខ្ញុំសូមថ្លែងអំណរគុណជាអនេកប្បការរកទីបំផុតគ្មាន ចំពោះឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាគណៈកម្មាធិការសមាគមមិត្តបុគ្គលិកកសិកម្មកម្ពុជា ដែលតែងតែយកចិត្តទុកដាក់ចំពោះទុក្ខលំបាករបស់មន្ត្រីរាជការក្រោមឱវាទក្រសួង ដែលបានទទួលមរណភាព ក្នុងនោះ ក្រសួងបានចាត់តាំងជាប្រតិភូសមាគម និងប្រតិភូសាខាសមាគមប្រចាំអគ្គនាយកដ្ឋានកសិកម្ម (នាយកដ្ឋានវិស្វកម្មកសិកម្ម) ចុះដល់គេហដ្ឋានយើងខ្ញុំ ដោយនាំមកជាមួយនូវថវិកាសមាគមចំនួន ៣ ០០០ ០០០រៀល(បីលានរៀល) ឧបត្ថម្ភដល់យើងខ្ញុំដែលជាគ្រួសារនៃសព សម្រាប់យកទៅចាត់ចែងប្រើប្រាស់ក្នុងពិធីបុណ្យទៅតាមសេចក្តីត្រូវការ។ ស្របពេលជាមួយនេះដែរ ឯកឧត្តមតែងតែផ្តាំផ្ញើនូវពាក្យពេចន៍ដ៏មានខ្លឹមសារ និងចំណុចល្អៗជាច្រើន ក្នុងការចូលរួមសម្រាលនូវទុក្ខសោកដ៏សែនខ្លោចផ្សានេះ។ នេះសបញ្ជាក់ឱ្យឃើញថា សកម្មភាព កាយវិការ សន្តានចិត្តជាព្រហ្មវិហារធម៌ដ៏ប្រពៃរកអ្វីប្រៀបគ្មាន និយាយដោយឡែក ចំពោះគ្រួសារយើងខ្ញុំដែលមានទុក្ខ និយាយជារួម ជាសីលធម៌ដ៏ល្អឥតខ្ចោះ រវាងថ្នាក់ដឹកនាំក្រសួង ជាមួយកូនចៅ មន្ត្រីរាជការក្រោមឱវាទ។

យើងខ្ញុំសូមគោរពជូនពរឯកឧត្តមរដ្ឋមន្ត្រី គណៈកម្មាធិការសមាគម មន្ត្រីរាជការក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំងអស់ សូមជួបនឹងពុទ្ធពរទាំងបួនប្រការ គឺ៖ អាយុៈ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕ សូមអរគុណ ៕

ថ្ងៃពុធ ៩រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៨
តំណាងក្រុមគ្រួសារសព